# សេចក្ដីជូនដំណឹងអំពីការអនុវត្តឯកជនភាព
# កម្មវិធីព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន

## យើងប្ដេជ្ញាចិត្តការពារឯកជនភាពរបស់អ្នក

ច្បាប់សហព័ន្ធការពារការរក្សាការសម្ងាត់នៃកំណត់ត្រាអ្នកជំងឺប្រើប្រាស់សារធាតុញៀន។

សេចក្ដីជូនដំណឹងនេះពិពណ៌នាអំពី៖

- របៀបដែលព័ត៌មានសុខភាពអំពីអ្នកអាចត្រូវបានប្រើប្រាស់ និងបង្ហាញ
- សិទ្ធិរបស់អ្នកទាក់ទងនឹងព័ត៌មានសុខភាពរបស់អ្នក
- របៀបដាក់ពាក្យបណ្ដឹងទាក់ទងនឹងការបំពានលើឯកជនភាព ឬសន្តិសុខនៃព័ត៌មានសុខភាពរបស់អ្នក ឬសិទ្ធិរបស់អ្នកទាក់ទងនឹងព័ត៌មានរបស់អ្នក

អ្នកមានសិទ្ធិទទួលបានច្បាប់ចម្លងនៃសេចក្ដីជូនដំណឹងនេះ (ជាទម្រង់ក្រដាស ឬអេឡិចត្រូនិក) និងពិភាក្សាវាជាមួយការិយាល័យឯកជនភាពនៃអង្គការ COREWELL HEALTH តាមរយៈ: លេខ **616.486.4113** ឬអ៊ីមែល **privacy@corewellhealth.org** ប្រសិនបើអ្នកមានសំណួរណាមួយ។

ឯកជនភាពនៃព័ត៌មានសុខភាពរបស់អ្នកតែងតែជាអាទិភាពនៅអង្គការ Corewell Health។ សេចក្ដីជូនដំណឹងនេះផ្ដល់ជូនអ្នកជំងឺប្រើប្រាស់សារធាតុញៀននៅអង្គការ Corewell Health នូវព័ត៌មានអំពីសិទ្ធិឯកជនភាពរបស់ពួកគេ និងការប្ដេជ្ញាចិត្តជាបន្តបន្ទាប់របស់អង្គការ Corewell Health ក្នុងការការពារសិទ្ធិទាំងនោះ។ អ្នកមានសិទ្ធិធ្វើការជ្រើសរើសអំពីរបៀបដែលព័ត៌មានសុខភាពរបស់អ្នកត្រូវបានប្រមូល និងប្រើប្រាស់។

## សេចក្ដីជូនដំណឹងអំពីការអនុវត្តឯកជនភាព

សេចក្ដីជូនដំណឹងនេះពិពណ៌នាអំពីរបៀបដែលព័ត៌មានព្យាបាលជំងឺប្រើប្រាស់សារធាតុញៀនអំពីអ្នកអាចត្រូវបានប្រើប្រាស់ និងបង្ហាញ និងរបៀបដែលអ្នកអាចទទួលបានព័ត៌មាននេះ។ សេចក្ដីជូនដំណឹងនេះនឹងផ្ដល់ជូនអ្នកនៅពេលទទួលយកអ្នកចូលក្នុងកម្មវិធីព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន ឬប្រសិនបើអ្នកមិនអាចយល់បានដោយសារតែស្ថានភាពសុខភាពរបស់អ្នកនៅពេលនោះ សូមផ្ដល់ព័ត៌មាននោះភ្លាមៗនៅពេលដែលអ្នកអាចធ្វើបាន។ សូមមើលសេចក្ដីជូនដំណឹងនេះដោយយកចិត្តទុកដាក់។ សេចក្ដីជូនដំណឹងនេះមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2026។

## អ្នកណានឹងអនុវត្តតាមសេចក្ដីជូនដំណឹងនេះ

សេចក្ដីជូនដំណឹងនេះអនុវត្តចំពោះកម្មវិធី ឬអ្នកផ្ដល់សេវារបស់អង្គការ Corewell Health ដែលផ្ដល់ការព្យាបាល ឬសេវាកម្មព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន ក្រោមមាត្រា 42 CFR ផ្នែកទី 2 (ផ្នែកទី 2)។ ខ្លឹមសារផ្លាស់ប្ដូរណាមួយនៅក្នុងសេចក្ដីជូនដំណឹងអំពីការអនុវត្តឯកជនភាពនេះ អាចរកបាននៅការិយាល័យ ឬមណ្ឌលដែលអ្នកកំពុងទទួលការថែទាំ ដោយទូរសព្ទទៅលេខ **616.486.4113** ឬដោយផ្ញើអ៊ីមែលទៅ **privacy@corewellhealth.org**។

## ការសន្យារបស់យើងក្នុងការការពារព័ត៌មានសុខភាពរបស់អ្នក

យើងយល់ថា ព័ត៌មានសុខភាពរបស់អ្នកគឺជារឿងឯកជន ហើយយើងប្ដេជ្ញាចិត្តការពារវា។ ព័ត៌មានសុខភាពដែលយើងប្រើប្រាស់ បង្កើត រក្សាទុក និងបង្ហាញអំពីអ្នកអាចទាក់ទងនឹងការថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្តដែលអ្នកទទួលបានពីយើង និងកម្មវិធីផ្នែកទី 2 របស់យើង។ យើងបង្កើតកំណត់ត្រាអំពីការថែទាំ និងសេវាកម្មដែលអ្នកទទួលបានពីអង្គការ Corewell Health។ កំណត់ត្រានេះអនុញ្ញាតឱ្យយើងផ្ដល់ជូនអ្នកនូវការថែទាំដែលមានគុណភាព និងអនុវត្តតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់មួយចំនួន។ សេចក្ដីជូនដំណឹងនេះអនុវត្តចំពោះកំណត់ត្រាផ្នែកទី 2 ដែលទាក់ទងនឹងការថែទាំរបស់អ្នក ដែលត្រូវបានរក្សាទុកដោយអង្គការ Corewell Health មិនថាជាទម្រង់អេឡិចត្រូនិក ឬក្រដាសនោះទេ។ ប្រសិនបើវេជ្ជបណ្ឌិតដែលផ្ដល់ការថែទាំដល់អ្នកមិនមែនជាសមាជិកក្រុមអង្គការ Corewell Health ពួកគេអាចមានគោលការណ៍ ឬសេចក្ដីជូនដំណឹងខុសពីនេះទាក់ទងនឹងការប្រើប្រាស់ និងការបង្ហាញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក។ សេចក្ដីជូនដំណឹងនេះប្រាប់អ្នកអំពីវិធីដែលព័ត៌មានសុខភាពផ្នែកទី 2 របស់អ្នកត្រូវបានប្រើប្រាស់ ឬបង្ហាញ។ វាក៏ពិពណ៌នាអំពីសិទ្ធិរបស់អ្នក និងកាតព្វកិច្ចរបស់យើងទាក់ទងនឹងការប្រើប្រាស់ និងការបង្ហាញព័ត៌មានសុខភាពទាក់ទងនឹងជំងឺប្រើប្រាស់សារធាតុញៀនផងដែរ។

ច្បាប់តម្រូវឱ្យយើង៖

- រក្សាឯកជនភាព និងសន្តិសុខនៃព័ត៌មានសុខភាពដែលបានការពារ (PHI) របស់អ្នក រួមទាំងព័ត៌មានសុខភាពផ្នែកទី 2 របស់អ្នក។
- ផ្ដល់ជូនអ្នកជំងឺនូវសេចក្ដីជូនដំណឹងអំពីកាតព្វកិច្ចចំពោះមុខច្បាប់ និងការអនុវត្តឯកជនភាពរបស់យើងទាក់ទងនឹងកំណត់ត្រាផ្នែកទី 2។
- គោរពតាមការអនុវត្តឯកជនភាពដែលបានពិពណ៌នានៅក្នុងសេចក្ដីជូនដំណឹងដែលចូលជាធរមាននាពេលបច្ចុប្បន្ន។
- ផ្ដល់ជូនអ្នកនូវច្បាប់ចម្លងនៃសេចក្ដីជូនដំណឹងនេះតាមសំណើ។
- ជូនដំណឹងដល់បុគ្គលដែលរងផលប៉ះពាល់បន្ទាប់ពីការបំពានលើព័ត៌មានសុខភាពដែលមិនមានសុវត្ថិភាព រួមទាំងព័ត៌មានអំពីជំងឺប្រើប្រាស់សារធាតុញៀន។

## សិទ្ធិផ្ដល់ការយល់ព្រម និងការដកហូត

អ្នកអាចផ្ដល់ការយល់ព្រមតែមួយសម្រាប់ការប្រើប្រាស់ ឬការបង្ហាញព័ត៌មាននាពេលអនាគតទាំងអស់សម្រាប់គោលបំណងព្យាបាល ការបង់ប្រាក់ ឬប្រតិបត្តិការថែទាំសុខភាពសម្រាប់ព័ត៌មានសុខភាពផ្នែកទី 2 របស់អ្នក (របៀបដែលព័ត៌មានបែបនេះអាចត្រូវបានប្រើប្រាស់ត្រូវបានពិភាក្សាបន្ថែមខាងក្រោម)។ អ្នកអាចដកហូតការយល់ព្រមរបស់អ្នកនៅពេលណាក៏បាន លើកលែងតែក្នុងវិសាលភាពដែលអង្គការ Corewell Health បានធ្វើសកម្មភាពដោយពឹងផ្អែកលើការយល់ព្រមនេះ។។ កំណត់ត្រាដែលត្រូវបានបង្ហាញទៅកម្មវិធីផ្នែកទី 2 អង្គភាពដែលទទួលបានការធានារ៉ាប់រង ឬដៃគូអាជីវកម្មស្របតាមការយល់ព្រម

ជាលាយលក្ខណ៍អក្សរពីអ្នកជំងឺសម្រាប់ការព្យាបាល ការបង់ប្រាក់ និងប្រតិបត្តិការថែទាំសុខភាព អាចត្រូវបានបង្ហាញបន្ថែមទៀតដោយកម្មវិធីផ្នែកទី 2 អង្គភាពដែលទទួលបានការធានារ៉ាប់រង ឬដៃគូអាជីវកម្ម ដោយមិនចាំបាច់មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជំងឺម្តងទៀតឡើយ ក្រោមវិសាលភាពដែលបទប្បញ្ញត្តិ HIPAA អនុញ្ញាតឲ្យមានការបង្ហាញព័ត៌មានបែបនេះ។

## របៀបដែលយើងអាចប្រើប្រាស់ និងបង្ហាញព័ត៌មានសុខភាពរបស់អ្នក

**សម្រាប់ការព្យាបាល៖** យើងអាចប្រើប្រាស់ព័ត៌មានសុខភាពរបស់អ្នក ហើយបង្ហាញព័ត៌មាននេះដល់អ្នកជំនាញផ្សេងទៀតដែលកំពុងព្យាបាលអ្នក។ ឧទាហរណ៍ វេជ្ជបណ្ឌិតដែលព្យាបាលរបួសអ្នកស្នើសុំអ្នកផ្តល់សេវាថែទាំសុខភាពម្នាក់ទៀតអំពីស្ថានភាពសុខភាពទូទៅរបស់អ្នក។

យើងអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកដើម្បីគោលបំណងបន្តផ្តល់ការថែទាំ។ ផ្នែកផ្សេងៗរបស់អង្គការ Corewell Health អាចបង្ហាញព័ត៌មានសុខភាពរបស់អ្នក ដើម្បីសម្របសម្រួលបញ្ហាផ្សេងៗដែលអ្នកត្រូវការ ដូចជាវេជ្ជបញ្ជា ការងារមន្ទីរពិសោធន៍ ការថតកាំរស្មីអ៊ិច ឬការព្យាបាល ឬដើម្បីសម្របសម្រួលការបញ្ជូនបន្ត។

**សម្រាប់ការបង់ប្រាក់៖** យើងអាចប្រើប្រាស់ និងបង្ហាញព័ត៌មានសុខភាព និងព័ត៌មានមិនមែនសុខភាពរបស់អ្នក ដើម្បីចេញវិក្កយបត្រ និងទទួលបានការបង់ប្រាក់សម្រាប់គម្រោងសុខភាពនានា ឬអង្គភាពផ្សេងទៀតសម្រាប់ការព្យាបាល និងសេវាកម្មដែលអ្នកទទួលបាននៅអង្គការ Corewell Health។ ឧទាហរណ៍ យើងអាចផ្តល់ព័ត៌មានអំពីអ្នកទៅឲ្យគម្រោងធានារ៉ាប់រងសុខភាពរបស់អ្នក ដូច្នេះគម្រោងនេះនឹងបង់ប្រាក់សម្រាប់ការថែទាំសុខភាព ឬសេវាកម្មរបស់អ្នក។ យើងអាចប្រាប់គម្រោងសុខភាពរបស់អ្នកអំពីការព្យាបាលដែលអ្នកនឹងទទួលបាន ដើម្បីទទួលបានការអនុម័តយល់ព្រមជាមុន ឬកំណត់ថាតើគម្រោងរបស់អ្នកនឹងរ៉ាប់រងលើការព្យាបាលឬអត់។

ប្រសិនបើអ្នកបានបង់ប្រាក់គ្រប់ចំនួនសម្រាប់ទំនិញ ឬសេវាកម្មថែទាំសុខភាព ហើយអ្នកប្រាប់យើងថាអ្នកមិនចង់ឱ្យគម្រោងសុខភាពរបស់អ្នកទទួលបានព័ត៌មានអំពីទំនិញ ឬសេវាកម្មនោះទេ យើងនឹងមិនបង្ហាញព័ត៌មាននោះទៅគម្រោងសុខភាពរបស់អ្នកទេ លុះត្រាតែច្បាប់តម្រូវឱ្យយើងធ្វើដូច្នេះ។

**សម្រាប់ប្រតិបត្តិការថែទាំសុខភាព៖** យើងអាចប្រើប្រាស់ និងបង្ហាញព័ត៌មានសុខភាពរបស់អ្នក ដើម្បីដំណើរការអាជីវកម្មរបស់យើង ដូចជាការធ្វើបញ្ជីគណនេយ្យ ការដំណើរការបណ្តឹងទាមទារសំណង ឬដើម្បីវាយតម្លៃធនធានមនុស្សរបស់យើង។ ការប្រើប្រាស់ និងការបង្ហាញព័ត៌មានទាំងនេះ គឺចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់អង្គការ Corewell Health និងដើម្បីធានាថាអ្នកជំងឺទាំងអស់របស់យើងទទួលបានការថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់។

យើងអាចរួមបញ្ចូលព័ត៌មានសុខភាពដែលយើងមាន ជាមួយនឹងព័ត៌មានសុខភាពពីអង្គការផ្សេងទៀត ដើម្បីប្រៀបធៀបសមត្ថភាពការងាររបស់យើង និងកំណត់ពីរបៀបដែលយើងអាចកែលម្អការថែទាំ និងសេវាកម្មដែលយើងផ្តល់ជូន។

**សវនកម្មលើការគ្រប់គ្រង សវនកម្មហិរញ្ញវត្ថុ និង ការវាយតម្លៃកម្មវិធី៖** យើងអាចបង្ហាញព័ត៌មានរបស់អ្នកទៅកាន់អ្នកដែលទទួលខុសត្រូវក្នុងការធ្វើសកម្មភាពសវនកម្ម និងវាយតម្លៃមួយជាក់លាក់ ដរាបណាបុគ្គលនោះយល់ព្រមចំពោះការដាក់កំហិតមួយចំនួនលើការបង្ហាញព័ត៌មាន។ សវនកម្មរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះសវនកម្មដែលធ្វើឡើងដោយទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធ រដ្ឋ និងមូលដ្ឋាន ព្រមទាំងអ្នកបង់ប្រាក់ជាភាគីទីបី និង/ឬគម្រោងសុខភាព ដើម្បីត្រួតពិនិត្យតាមដានប្រព័ន្ធថែទាំសុខភាព កម្មវិធីរដ្ឋាភិបាល និងការអនុលោមតាមច្បាប់សិទ្ធិស៊ីវិល។

## របៀបដែលយើងអាចប្រើប្រាស់និងបង្ហាញព័ត៌មានសុខភាពរបស់អ្នក – ស្ថានភាពពិសេស

**សង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ៖** ក្នុងករណីមានបញ្ហាសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ យើងអាចបង្ហាញព័ត៌មានដែលកំណត់អត្តសញ្ញាណអ្នកជំងឺដោយមិនចាំបាច់មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកទេ ប៉ុន្តែត្រូវអនុវត្តក្នុងវិសាលភាពចាំបាច់ដើម្បីជួយបុគ្គលិកពេទ្យងការឆ្លើយតបទៅនឹងសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

**កំណត់ចំណាំអំពីការប្រឹក្សា និងព័ត៌មានសម្ងាត់ខ្ពស់៖** ព័ត៌មានសុខភាពមួយចំនួនទទួលបានការការពារឯកជនភាពពិសេស ដូចជាកំណត់ចំណាំអំពីការព្យាបាលចិត្តសាស្ត្រ និងកំណត់ចំណាំការប្រឹក្សាអំពីជំងឺប្រើប្រាស់សារធាតុញៀន (កំណត់ចំណាំដែលរក្សាទុកដោយឡែកពីគ្នាដោយគ្រូពេទ្យដែលវិភាគវគ្គប្រឹក្សា) សេវាកម្មនានាសម្រាប់សុខភាពផ្លូវចិត្ត និងពិការភាពផ្នែកលូតលាស់ និងជំងឺមួយចំនួន។ យើងនឹងប្រើប្រាស់ ឬចែករំលែកព័ត៌មានវេជ្ជសាស្ត្រសម្ងាត់ខ្ពស់របស់អ្នក លុះត្រាតែមានការអនុញ្ញាត ឬតម្រូវដោយច្បាប់ ឬដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នក។

ទោះជាយ៉ាងណាក៏ដោយ សម្រាប់កំណត់ចំណាំអំពីការប្រឹក្សាផ្នែកទី 2 យើងអាចបង្ហាញព័ត៌មានទាំងនោះដោយមិនចាំបាច់មានការយល់ព្រមជាលាយលក្ខណ៍អក្សរសម្រាប់ (i) ការព្យាបាលដោយអ្នកផ្តល់សេវាដែលបានបង្កើតកំណត់ចំណាំអំពីការប្រឹក្សា (ii) កម្មវិធីបណ្តុះបណ្តាលរបស់សិស្ស សិក្ខាកាម ឬអ្នកជំនាញក្នុងការព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន (SUD) ឬកម្មវិធីសុខភាពផ្លូវចិត្ត និង/ឬ (iii) សម្រាប់ការការពាររបស់អង្គការ Corewell Health ក្នុងចំណាត់ការផ្លូវច្បាប់ ឬបណ្តឹងផ្សេងទៀតដែលធ្វើឡើងដោយអ្នកជំងឺ។

**ហានិភ័យចំពោះសុខភាពសាធារណៈ៖** យើងអាចបង្ហាញព័ត៌មានសុខភាពសម្រាប់សកម្មភាពសុខភាពសាធារណៈ: ដើម្បីទប់ស្កាត់ ឬគ្រប់គ្រងជំងឺ របួស ឬពិការភាព។ ព័ត៌មានដែលបានផ្តល់ចាំបាច់ត្រូវបានលុបអត្តសញ្ញាណ ដើម្បីកុំឱ្យមានមូលដ្ឋានហេតុផលណាមួយក្នុងការជឿថាព័ត៌មាននេះអាចត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណអ្នក។

**សកម្មភាពរៃអង្គាសថវិកា៖** អង្គការ Corewell Health អាចប្រើប្រាស់ ឬបង្ហាញឯកសារដើម្បីរៃអង្គាសប្រាក់សម្រាប់អត្ថប្រយោជន៍នៃកម្មវិធីផ្នែកទី 2 លុះត្រាតែអ្នក ដែលជាអ្នកជំងឺ ទទួលបានឱកាសត្រឹមត្រូវ និងច្បាស់លាស់ជាមុនសិន ដើម្បីជ្រើសរើសមិនទទួលការទំនាក់ទំនងរៃអង្គាសប្រាក់។ ប្រសិនបើអ្នកយល់ព្រម

យើងអាចប្រើប្រាស់ព័ត៌មានមិនមែនវេជ្ជសាស្ត្រមួយចំនួន ដើម្បីទាក់ទងអ្នក ដើម្បីរៃអង្គាសប្រាក់សម្រាប់សាខាអង្គការ Corewell Health តាមរយៈមូលនិធិដែលស្ថិតក្រោម ឬគ្រប់គ្រងដោយអង្គការ Corewell Health។

**ឧក្រិដ្ឋកម្មលើបរិវេណអង្គការ៖** យើងអាចបង្ហាញព័ត៌មានដល់មន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋលើបរិវេណអង្គការ ឬប្រឆាំងនឹងបុគ្គលិករបស់យើង ឬការគំរាមកំហែងដើម្បីប្រព្រឹត្តបទឧក្រិដ្ឋបែបនេះ។

**ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ៖** ប្រសិនបើអ្នកត្រូវបានបង្គាប់ឱ្យទទួលការព្យាបាលតាមរយៈប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ (រួមទាំងតុលាការដោះស្រាយគ្រឿងញៀន ការព្យួរទោស ឬការដោះលែងដោយមានលក្ខខណ្ឌជាមុន) ហើយអ្នកចុះហត្ថលេខាលើការយល់ព្រមអនុញ្ញាតឱ្យបង្ហាញព័ត៌មានចំពោះធាតុផ្សំនៃប្រព័ន្ធច្បាប់ព្រហ្មទណ្ឌដូចជាតុលាការ មន្ត្រីព្យួរទោស មន្ត្រីដោះលែងដោយមានលក្ខខណ្ឌជាមុន រដ្ឋអាជ្ញា ឬមន្ត្រីអនុវត្តច្បាប់ផ្សេងទៀត សិទ្ធិរបស់អ្នកក្នុងការដកហូតការយល់ព្រមអាចមានដែនកំណត់ច្រើនជាងនេះ ហើយគួរតែធ្វើការពន្យល់ឲ្យបានច្បាស់នៅលើលិខិតយល់ព្រមដែលអ្នកចុះហត្ថលេខា។

**ការការពារផ្នែកច្បាប់៖** កំណត់ត្រា ឬសក្ខីកម្មដែលបញ្ជូនបន្តខ្លឹមសារនៃឯកសារបែបនេះ មិនត្រូវបានប្រើប្រាស់ ឬបង្ហាញនៅក្នុងដំណើរការរដ្ឋប្បវេណី រដ្ឋបាល ព្រហ្មទណ្ឌ ឬនីតិប្បញ្ញត្តិណាមួយប្រឆាំងនឹងអ្នកទេ លុះត្រាតែផ្អែកលើការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់ពី ឬដីកាបង្គាប់របស់តុលាការ។ កំណត់ត្រានឹងត្រូវបានប្រើប្រាស់ ឬបង្ហាញដោយផ្អែកលើដីកាតុលាការ បន្ទាប់ពីការជូនដំណឹង និងឱកាសដើម្បីចូលសវនការត្រូវបានផ្តល់ជូនអ្នក (អ្នកជំងឺ) និង/ឬអ្នកកាន់កាប់កំណត់ត្រាដូចដែលមានចែងក្នុងមាត្រា 42 USC § 290dd-2 និង 42 CFR ផ្នែកទី 2។ ដីកាបង្គាប់របស់តុលាការដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬបង្ហាញចាំបាច់ត្រូវអមមានភ្ជាប់មកជាមួយដីកាកោះហៅ ឬអាណត្តិផ្លូវច្បាប់ស្រដៀងគ្នាផ្សេងទៀត ដែលតម្រូវឲ្យមានការបង្ហាញព័ត៌មានដ៏គួរឱ្យជឿជាក់ មុនពេលដែលប្រើប្រាស់ ឬបង្ហាញកំណត់ត្រាទាំងនេះ។

**ការស្រាវជ្រាវ៖** យើងអាចប្រើប្រាស់ និងបង្ហាញព័ត៌មានរបស់អ្នកសម្រាប់ការស្រាវជ្រាវ ក្នុងករណីបំពេញបានតាមលក្ខខណ្ឌតម្រូវជាក់លាក់។

**របាយការណ៍អំពីករណីសង្ស័យការបំពាន និងការធ្វេសប្រហែសលើកុមារ៖** យើងអាចបង្ហាញព័ត៌មានដែលតម្រូវឱ្យរាយការណ៍តាមផ្លូវច្បាប់អំពីករណីសង្ស័យការបំពាន និងការធ្វេសប្រហែសលើកុមារទៅកាន់អាជ្ញាធររដ្ឋ ឬអាជ្ញាធរមូលដ្ឋានដែលមានសមត្ថកិច្ច។ ទោះជាយ៉ាងណាក៏ដោយ យើងអាចមិនបង្ហាញកំណត់ត្រាច្បាប់ដើមរបស់អ្នកជំងឺ រួមទាំងសម្រាប់ដំណើរការរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលអាចកើតឡើងចេញពីរបាយការណ៍អំពីករណីសង្ស័យការបំពាន និងការធ្វេសប្រហែសលើកុមារ ដោយគ្មានការយល់ព្រមឡើយ។

**ការរាយការណ៍អំពីមរណភាព៖** យើងអាចបង្ហាញព័ត៌មានរបស់អ្នកទាក់ទងនឹងមូលហេតុនៃមរណភាពទៅកាន់អាជ្ញាធរសុខាភិបាលសាធារណៈដែលមានសិទ្ធិទទួលបានព័ត៌មានបែបនេះ។

**ការប្រើប្រាស់ផ្សេងទៀតនៃព័ត៌មានសុខភាពរបស់អ្នក៖** ការប្រើប្រាស់ និងការបង្ហាញព័ត៌មានសុខភាពផ្សេងទៀតដែលមិនបានលើកឡើងក្នុងសេចក្តីជូនដំណឹងនេះ ឬច្បាប់ដែលអនុវត្តចំពោះអង្គការ Corewell Health នឹងត្រូវបានធ្វើឡើងលុះត្រាតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នក។ ប្រសិនបើអ្នកផ្តល់ការអនុញ្ញាតឱ្យយើងប្រើប្រាស់ ឬបង្ហាញព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក អ្នកអាចដកហូតការអនុញ្ញាតនោះជាលាយលក្ខណ៍អក្សរនៅពេលណាក៏បាន។ ប្រសិនបើអ្នកដកហូតការអនុញ្ញាតរបស់អ្នក យើងនឹងមិនប្រើប្រាស់ ឬបង្ហាញព័ត៌មានសុខភាពអំពីអ្នកសម្រាប់ហេតុផលដែលមាននៅក្នុងលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។ យើងមិនអាចបដិសេធការបង្ហាញព័ត៌មានណាមួយដែលយើងបានធ្វើរួចហើយដោយមានការអនុញ្ញាតពីអ្នកបានទេ ហើយយើងតម្រូវឱ្យរក្សាទុកកំណត់ត្រារបស់យើងអំពីការថែទាំដែលយើងបានផ្តល់ដល់អ្នក។

## សិទ្ធិរបស់អ្នកទាក់ទងនឹងព័ត៌មានសុខភាពរបស់អ្នក

**សិទ្ធិត្រួតពិនិត្យ និងចម្លង៖** អ្នកអាចស្នើសុំមើល ឬទទួលបានច្បាប់ចម្លងជាទម្រង់អេឡិចត្រូនិក ឬជាទម្រង់ក្រដាសនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក និងព័ត៌មានសុខភាពផ្សេងទៀតដែលយើងមានអំពីអ្នក។ ព័ត៌មានដែលមានសម្រាប់អ្នករួមមានកំណត់ត្រាវេជ្ជសាស្ត្រនិងវិក្កយបត្រ ប៉ុន្តែមិនរួមបញ្ចូលកំណត់ចំណាំអំពីការព្យាបាលចិត្តសាស្ត្រណាមួយឡើយ។ យើងនឹងផ្តល់ច្បាប់ចម្លង ឬសេចក្តីសង្ខេបនៃព័ត៌មានសុខភាពរបស់អ្នក ជាទូទៅក្នុងរយៈពេល 30 ថ្ងៃគិតចាប់ពីថ្ងៃស្នើសុំរបស់អ្នក។ យើងអាចគិតថ្លៃសេវាសមរម្យដូចថ្លៃដើម។ យើងអាចបដិសេធសំណើរបស់អ្នកក្នុងការត្រួតពិនិត្យ និងចម្លងក្នុងកាលៈទេសៈមានកំណត់មួយចំនួន។ ប្រសិនបើអ្នកត្រូវបានបដិសេធមិនឱ្យទទួលបានព័ត៌មានសុខភាព អ្នកអាចស្នើសុំឱ្យពិនិត្យមើលឡើងវិញនូវការបដិសេធ។ អ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាបណ្ណផ្សេងទៀតដែលត្រូវបានជ្រើសរើសដោយអង្គការ Corewell Health នឹងពិនិត្យមើលសំណើ និងការបដិសេធរបស់អ្នក។ អ្នកដែលធ្វើការពិនិត្យមើលនឹងមិនមែនជាបុគ្គលដែលបានបដិសេធសំណើដំបូងរបស់អ្នកទេ។ យើងនឹងអនុវត្តតាមលទ្ធផលនៃការពិនិត្យមើលឡើងវិញ។ ប្រសិនបើអ្នកកំពុងចូលរួមក្នុងសកម្មភាពស្រាវជ្រាវនានា យើងអាចបដិសេធសំណើរបស់អ្នកក្នុងការពិនិត្យមើលឡើងវិញ និងចម្លងព័ត៌មានសុខភាពមួយចំនួនរបស់អ្នកដែលទាក់ទងនឹងការស្រាវជ្រាវនោះ ដរាបណាអ្នកបានយល់ព្រមចំពោះការដាក់កំហិតលើការទទួលបាននេះនៅក្នុងទម្រង់លិខិតយល់ព្រមដែលអ្នកបានចុះហត្ថលេខាមុននឹងចូលរួម។ យើងក៏អាចបដិសេធការចូលប្រើប្រាស់ផងដែរ ដូចដែលច្បាប់អនុញ្ញាតតាមវិធីផ្សេងពីនេះ។

**សិទ្ធិកែតម្រូវ៖** អ្នកអាចស្នើសុំឱ្យផ្នែកគ្រប់គ្រងព័ត៌មានសុខភាពកែតម្រូវព័ត៌មានសុខភាពរបស់អ្នកណាមួយដែលអ្នកគិតថាមិនត្រឹមត្រូវ ឬមិនពេញលេញ។ យើងអាចនិយាយ "ទេ" ចំពោះសំណើរបស់អ្នក ប៉ុន្តែយើងនឹងប្រាប់អ្នកពីមូលហេតុជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 60 ថ្ងៃ។ យើងអាចបដិសេធសំណើរបស់អ្នកសុំការកែតម្រូវណាមួយ ប្រសិនបើវាមិនបានស្នើសុំជាលាយលក្ខណ៍អក្សរ ឬមិនមានហេតុផលដើម្បីគាំទ្រសំណើនេះ។ យើងក៏អាចបដិសេធសំណើរបស់អ្នកផងដែរ ប្រសិនបើអ្នកស្នើសុំឱ្យយើងកែតម្រូវព័ត៌មានដែល៖

- មិនត្រូវបានបង្កើតឡើងដោយយើងទេ លុះត្រាតែបុគ្គល ឬអង្គភាពដែលបានបង្កើតព័ត៌មាននោះមិនអាចធ្វើការកែតម្រូវបន្តទៀត។
- មិនមែនជាផ្នែកមួយនៃព័ត៌មានសុខភាពដែលរក្សាទុកដោយ ឬសម្រាប់អង្គភាពរបស់អង្គការ Corewell Health។
- មិនមែនជាផ្នែកមួយនៃព័ត៌មានដែលអ្នកនឹងត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលឡើងវិញ និងចម្លងនោះទេ។
- មានភាពត្រឹមត្រូវ និងពេញលេញ។

**សិទ្ធិទទួលបានរបាយការណ៍អំពីការបង្ហាញព័ត៌មាន៖** អ្នកអាចស្នើសុំបញ្ជី (របាយការណ៍) នៃកំណត់ត្រានានាដែលយើងបានចែករំលែកព័ត៌មានសុខភាពរបស់អ្នករយៈពេលបីឆ្នាំមុនកាលបរិច្ឆេទដែលអ្នកស្នើសុំ អ្នកណាខ្លះដែលយើងបានចែករំលែកវាជាមួយ និងគោលបំណង។ សូមផ្នែកគ្រប់គ្រងព័ត៌មានសុខភាពអំពីរបៀបស្នើសុំរបាយការណ៍នេះ។ យើងនឹងរួមបញ្ចូលការបង្ហាញព័ត៌មានទាំងអស់លើកលែងតែព័ត៌មានអំពីការព្យាបាល ការបង់ប្រាក់ និងប្រតិបត្តិការថែទាំសុខភាព និងការបង្ហាញព័ត៌មានមួយចំនួនទៀត (ដូចជាអ្វីដែលអ្នកបានស្នើសុំឱ្យយើងធ្វើ)។ យើងនឹងផ្តល់ជូនរបាយការណ៍មួយក្នុងមួយឆ្នាំដោយឥតគិតថ្លៃ ប៉ុន្តែនឹងគិតថ្លៃសេវាសមរម្យដូចថ្លៃដើម ប្រសិនបើអ្នកស្នើសុំម្តងទៀតក្នុងរយៈពេល 12 ខែ។ សំណើរបស់អ្នកគួរតែបញ្ជាក់ក្នុងទម្រង់ណាមួយដែលអ្នកចង់បានបញ្ជី (ឧទាហរណ៍ ជាទម្រង់ក្រដាស ឬជាទម្រង់អេឡិចត្រូនិក)។

**សិទ្ធិស្នើសុំដាក់កំហិត៖** អ្នកអាចស្នើសុំឱ្យយើងមិនប្រើប្រាស់ ឬបង្ហាញព័ត៌មានសុខភាពមួយចំនួនសម្រាប់ការព្យាបាល ការបង់ប្រាក់ ឬប្រតិបត្តិការរបស់យើង។ ប្រសិនបើអ្នកបង់ប្រាក់គ្រប់ចំនួនដោយផ្ទាល់ខ្លួនសម្រាប់ថ្លៃសេវាកម្ម ឬទំនិញថែទាំសុខភាព អ្នកអាចស្នើសុំឱ្យយើងមិនចែករំលែកព័ត៌មាននោះជាមួយក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់អ្នក។ យើងនឹងនិយាយ "បាទ/ចាស" លុះត្រាតែច្បាប់តម្រូវឱ្យយើងចែករំលែកព័ត៌មាននោះ ប្រសិនបើវានឹងប៉ះពាល់ដល់ការថែទាំរបស់អ្នក ឬប្រសិនបើយើងមិនអាចអនុវត្តតាមសំណើរបស់អ្នក។

**សិទ្ធិស្នើសុំការទំនាក់ទំនងជាសម្ងាត់៖** អ្នកអាចស្នើសុំឱ្យយើងទំនាក់ទំនងជាមួយអ្នកអំពីបញ្ហាថែទាំសុខភាពតាមរបៀបជាក់លាក់មួយ ឬនៅទីតាំងជាក់លាក់មួយ។ ឧទាហរណ៍ អ្នកអាចស្នើសុំឱ្យយើងទាក់ទងអ្នកតែនៅកន្លែងធ្វើការ ឬតាមប្រៃសណីយ៍ប៉ុណ្ណោះ។ យើងនឹងយល់ព្រមចំពោះរាល់សំណើសមហេតុផលទាំងអស់។ សំណើអាចធ្វើឡើងក្នុងអំឡុងពេលចុះឈ្មោះ ទៅកាន់តំណាងអ្នកជំងឺរបស់អ្នក ឬទៅកាន់ការិយាល័យឯកជនភាព។ យើងអាចស្នើសុំឱ្យអ្នកដាក់សំណើរបស់អ្នកជាលាយលក្ខណ៍អក្សរ។

## ដាក់ពាក្យបណ្តឹង

ប្រសិនបើអ្នកជឿថាសិទ្ធិឯកជនភាពរបស់អ្នកត្រូវបានបំពាន អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងជាមួយលេខាធិការនៃ U.S. Department of Health and Human Services (ក្រសួងសុខាភិបាល និងសេវាមនុស្សរបស់សហរដ្ឋអាមេរិក) និងអង្គការ Corewell Health។ អ្នកមិនតម្រូវឱ្យរាយការណ៍អំពីករណីចោទប្រកាន់ការរំលោភបំពានទៅកាន់លេខាធិការ ឬអង្គការ Corewell Health ទេ ប៉ុន្តែអាចរាយការណ៍ទៅមួយណាក៏បានដែរ ឬក៏ទាំងពីរ។ អ្នកនឹងមិនត្រូវបានពិន័យ ឬសងសឹកដោយសារដាក់ពាក្យបណ្តឹងនោះទេ។

ដាក់ពាក្យបណ្តឹងទៅការិយាល័យសិទ្ធិស៊ីវិលនៃក្រសួងសុខាភិបាល និងសេវាមនុស្សរបស់សហរដ្ឋអាមេរិក ដោយចូលទៅកាន់គេហទំព័រ **ocrportal.hhs.gov/ocr/smartscreen/main.jsf**។

ដើម្បីដាក់ពាក្យបណ្តឹងទៅអង្គការ Corewell Health អ្នកអាចទូរសព្ទទៅកាន់ Integrity Hotline ដោយឥតគិតថ្លៃតាមរយៈលេខ **877.319.0266** អ៊ីមែល **privacy@corewellhealth.org**, ឬដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅកាន់៖

Corewell Health
ATTN: Chief Privacy Officer MC6481
100 Corewell Drive NW
Grand Rapids, MI 49503

## ការផ្លាស់ប្តូរនៃសេចក្តីជូនដំណឹងនេះ

យើងសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរសេចក្តីជូនដំណឹងនេះ។ យើងក៏រក្សាសិទ្ធិក្នុងការធ្វើឱ្យមានប្រសិទ្ធភាពនៃសេចក្តីជូនដំណឹងដែលបានកែសម្រួលសម្រាប់ព័ត៌មានសុខភាពដែលយើងមានរួចហើយអំពីអ្នក និងព័ត៌មានណាមួយដែលយើងទទួលបាននាពេលអនាគត។ យើងនឹងបិទផ្សាយច្បាប់ចម្លងនៃសេចក្តីជូនដំណឹងបច្ចុប្បន្ននៅក្នុងមណ្ឌលសុខភាព ការិយាល័យ និងទីតាំងដូចដែលបានលើកឡើងក្នុងសេចក្តីជូនដំណឹងនេះ។ សេចក្តីជូនដំណឹងនឹងមានកាលបរិច្ឆេទដែលមានប្រសិទ្ធភាព។ លើសពីនេះ ច្បាប់ចម្លងនៃសេចក្តីជូនដំណឹងថ្មីចុងក្រោយបំផុតនឹងត្រូវបានផ្តល់ជូនអ្នករៀងរាល់ពេលដែលអ្នកចុះឈ្មោះជាមួយមណ្ឌលសុខភាព ឬការិយាល័យកម្មវិធីផ្នែកទី 2 ឬអ្នកត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងមណ្ឌលកម្មវិធីផ្នែកទី 2 សម្រាប់ការព្យាបាល ឬសេវាថែទាំសុខភាពជាអ្នកជំងឺសម្រាកព្យាបាលនៅក្នុងមណ្ឌល ឬអ្នកជំងឺខាងក្រៅ។